ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី១ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០

រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន
នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី១ សម្រាប់ឆ្នាំ២០២០ ក្រោមការដឹកនាំរបស់ **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង-ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍ និងជំងឺអេដស៍។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីបង្ហាញពីរបាយការណ៍វឌ្ឍនភាព សមិទ្ធផល និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងពិភាក្សាសម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណងនៃសិក្ខាសាលា

-បទអន្តរាគមន៍ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍សម្រាប់ក្រុមប្រឈមមុខខ្ពស់

-ការឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រសម្រាប់ប្រជាជនទូទៅ និងក្រុមប្រឈម

-ទិន្នន័យសង្ខេបឆ្នាំ២០១៨ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍(Snapshot)នៅកម្ពុជា

-មតិបូកសរុប និងបិទកម្មវិធី

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានកំណត់ ។

<u>ប្រធានបទទី១៖</u>

**លោកវេជ្ជ. ឡាន វណ្ណសេង** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគបានជម្រាបជូនថា ការអនុវត្តសកម្មភាពឆ្លើយតបមេរោគអេដស៍នៅកម្ពុជាស្របតាមផែនការយុទ្ធសាស្ត្រចំនួនពីរគឺ ផែនការយុទ្ធសាស្ត្រឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ជាពហុវិស័យ ២០១៩-២០២៣ ដឹកនាំផ្ទាល់ដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលធ្វើការជាមួយអន្តរក្រសួង និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត-ក្រុង ផែនការយុទ្ធសាស្ត្រជាតិមួយទៀតរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០២១-២០២៥ ដឹកនាំដោយក្រសួងសុខាភិបាលគឺ ការងារបង្ការ ថែទាំ និងការព្យាបាលអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍។

លោកវេជ្ជបណ្ឌិតមានប្រសាសន៍ថា បទបង្ហាញចង់បញ្ជាក់ជូនស្ថានភាពបច្ចុប្បន្ននៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅប្រទេសកម្ពុជានៅត្រង់ណា ហើយកំពុងធ្វើអ្វីខ្លះ?

តាមការប៉ាន់ស្មាននៃអ្នករស់នៅជាមួយមេរោគអេដស៍នៅឆ្នាំ២០១៨ មានចំនួន៧៣០០០នាក់ អ្នករស់នៅជាមួយមេរោគអេដស៍ កំពុងទទួលបានការព្យាបាលនៅដំណាច់ឆ្នាំ២០១៩ មានចំនួន ៦០,៤០០នាក់ និងចំនួនអ្នករស់នៅជាមួយមេរោគអេដស៍ ដែលមិនទាន់បានដឹងពីស្ថានភាពមេរោគអេដស៍របស់ខ្លួនមានចំនួនជាងមួយម៉ឺននាក់ ដូចនេះគោលដៅរបស់យើងគឺចង់ស្វែងរកអ្នកផ្ទុកមេរោគអេដស៍ដែលមិនមកទទួលសេវាទាំងនេះឱ្យមកទទួលសេវា និងទប់ស្កាត់កុំឱ្យមានករណីឆ្លងថ្មីបន្ថែមទៀត។

មានការសិក្សាស្រាវជ្រាវដើម្បីវាយតម្លៃទៅលើការឆ្លើយតបមេរោគអេដស៍ហៅថា ការរួមគ្នាពិនិត្យមើលកម្មវិធីឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍( Joint Programme Review )បានបង្ហាញឱ្យឃើញថា៖

- ក្រុមប្រជាជនប្រឈមមុខ( Key Population )មាន ក្រុមបុរសរួមភេទជាមួយបុរស( MSM ) ក្រុមបំប្លែងភេទ( TG ) ក្រុមស្ត្រីគ្រឹះស្ថានកម្សាន្តសប្បាយ( FEW )។
- ៤០%នៃករណីឆ្លងថ្មីមានក្នុងចំណោមប្រជាជនប្រឈមមុខដូចនេះបញ្ជាក់ថា៦០%នៃករណីថ្មីមានក្នុងចំណោមប្រជាជនទូទៅ។
- អាត្រាឆ្លងមេរោគអេដស៍ប្រែប្រួលតាមប្រភេទការងារកម្សាន្តសប្បាយដូចជា ស្ត្រីឯករាជ្យ ឬស្ត្រីតាមផ្លូវមានអាត្រាឆ្លងមេរោគអេដស៍ខ្ពស់គឺ១១.៨៥%។
- អាត្រាប្រើស្រោមអនាម័យពេលរួមភេទរបស់ស្ត្រីជាមួយដៃគូសង្សារក្រោម២៧.២%ទាបជាងឆ្នាំ២០១០ មានដល់ទៅ៣៩.៤%។

កញ្ចប់នៃបទអន្តរាគមន៍មានពីរប្រភេទ៖

- កញ្ចប់នៃបទអន្តរាគមន៍ដែលហៅថាម៉ូដែល
    - ការចុះអប់រំផ្ទាល់នៅសហគមន៍តាម រយៈអ្នកអប់រំផ្ទាល់ (OW)
    - Virtual Outreach
    - ការស្វែងរកករណីឆ្លងមេរោគអេដស៍ថ្មីតាមរយៈមិត្រភក្តិ ( PDI+ )
    - PrEP
- កញ្ចប់នៃបទអន្តរាគមន៍ដែលហៅថាសេវា៖
    - **នៅសហគមន៍** សារស្តីពីការបង្ការមេរោគអេដស៍ ការចែកចាយស្រោមអនាម័យ ទឹករំអិល ការធ្វើតេស្តឈាមរកមេរោគអេដស៍ និងជំងឺស្វាយ បញ្ជូនទៅពិនិត្យជំងឺកាមរោគ។
    - **នៅមូលដ្ឋានសុខាភិបាល** ការធ្វើតេស្តរកមេរោគអេដស៍ ជំងឺស្វាយ និងសេវាព្យាបាល។

<u>ប្រធានបទទី២៖</u>

**លោក ស្រ៊ុន រចនា** ទីប្រឹក្សាបច្ចេកទេសផ្នែកអំពើហិង្សា និងយេនឌ័រ( GBV )មកពីអង្គការFHI360 បានបង្ហាញពីការឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងមេរោគអេដស៍សម្រាប់ប្រជាជនទូទៅ និងក្រុមប្រឈម ដូចជា៖

ហេតុអ្វីចាំបាច់ត្រូវលើកពីអំពើហិង្សាទាក់ទងយេនឌ័រ ក្នុងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ ដោយសារយេនឌ័រ។ យេនឌ័រគឺការធ្វើឱ្យមានឱកាសស្មើគ្នាធ្វើឱ្យមានលទ្ធភាពស្មើគ្នារវាងបុរស និងស្ត្រី តាមការសង្កេតឃើញថា ជនរងគ្រោះពីអំពើហិង្សាយេនឌ័រអាចជាបុរស ឬអាចជាស្ត្រី តែភាគច្រើនជាស្ត្រី និងកុមារ ដែលក្នុងនោះមានក្រុមប្រឈមមួយចំនួនដូចជា ស្ត្រីបម្រើការងារតាមគ្រឹះស្ថានកម្សាន្តសប្បាយ បុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ។ តើអំពើហិង្សាយេនឌ័រ និងការបង្ការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ពាក់ព័ន្ធគ្នាយ៉ាងដូចម្តេច? ដូចនេះចាំបាច់ត្រូវយល់ពីនិយមន័យអំពើហិង្សាមានដូចជា៖

១. អំពើហិង្សាផ្លូវកាយ

២. អំពើហិង្សាផ្លូវចិត្ត

៣. អំពើហិង្សាផ្លូវភេទ

៤. អំពើហិង្សាផ្លូវសេដ្ឋកិច្ច

កាលណាមានអំពើហិង្សាជាហេតុបង្កឱ្យមានបញ្ហាប្រឈមមួយចំនួនដូចជា៖

-ការរើសអើងក្នុងការផ្តល់សេវា

-ប្រឈមនឹងការឆ្លងមេរោគអេដស៍ថ្មី

-ពិបាកមកទទួលសេវាសុខាភិបាល និងសង្គម

ទាំងនេះដែលនាំឱ្យប៉ះពាល់គោលដៅ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥។ ក្នុងការអនុវត្តការឆ្លើយតបអំពើហិង្សាយេនឌ័រ និងអេដស៍នេះមានបណ្តុំសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- បង្កើតក្រុមការងារថ្នាក់ខេត្តដែលមានគណៈកម្មាធិការស្ត្រី និងកុមារ
- បង្កើតក្រុមការងារបច្ចេកទេស
- រៀបចំកិច្ចប្រជុំ
- ប្រមូលព័ត៌មានចងក្រងសៀវភៅសេវាកម្មសម្រាប់ជនរងគ្រោះដោយអំពើហិង្សា
- រៀបចំគោលការណ៍ណែនាំសម្រាប់អ្នកផ្តល់សេវាក្នុងការឆ្លើយតបអំពើហិង្សាយេនឌ័រ
- របៀបផ្តល់សេវាបង្ការមេរោគអេដស៍មុនពេលរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ(PEP)
- ទំនាក់ទំនងលំហូរពីសេវាកម្មមួយទៅសេវាកម្មមួយទៀត
- បង្កើតប្រព័ន្ធរាយការណ៍ និងឆ្លើយតបនឹងសៀវភៅណែនាំការអនុវត្ត
- បង្កើតកម្មវិធីអេប(Apps)សម្រាប់តាមដានព័ត៌មាន(Information Tracking) ដែលជាប្រព័ន្ធមួយដើម្បីឱ្យអ្នកផ្តល់សេវាត្រៀមខ្លួនជាមុនដើម្បីផ្តល់ការឆ្លើយតបដល់ជនរងគ្រោះ។៥

__ប្រធានបទទី៣៖__

**លោកវេជ្ជ. ស៊ឹម ស្ងៃ** អនុប្រធាននាយកដ្ឋានផែនការ តាមដាន និងស្រាវជ្រាវ បង្ហាញពីការធ្វើបច្ចុប្បន្នភាព និងសង្ខេបទិន្នន័យស្តីពីមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ដើម្បីប្រើប្រាស់ឱ្យបានស្របគ្នាដោយស្ថាប័ន និងផ្នែកពាក់ព័ន្ធនឹងការប្រយុទ្ធនឹងជំងឺអេដស៍នៅព្រះរាជាណាចក្រកម្ពុជា។

តាមការប៉ាន់ប្រមាណឆ្នាំ២០១៨ នៅកម្ពុជាមាន៧៣,០០០នាក់ និងអ្នកបានទទួលសេវាចំនួន៥៩,៨៣៧នាក់ រីឯអត្រាប្រេវ៉ាឡង់អ្នកផ្ទុកមេរោគអេដស៍(អាយុពី១៥ឆ្នាំ ដល់៤៩ឆ្នាំ)មាន០.៥៤% និងចំនួនប៉ាន់ប្រមាណអ្នកឆ្លងថ្មីចំនួន៨៨០នាក់។

ចំពោះទិន្នន័យសង្ខេបស្តីពីមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ដែលរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងធ្វើការកែសម្រួល ហើយពិគ្រោះយោបល់ជាមួយផ្នែកព័ត៌មានយុទ្ធសាស្ត្រ(SI)របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគបន្ថែមទៀតមុននឹងបញ្ចប់។

__ប្រធានបទទី៤៖__

**លោកវេជ្ជ. ស្រី មុនី** ទីប្រឹក្សាបច្ចេកទេសរបស់អង្គការគោលនយោបាយសុខភាព បានចែករំលែកជូនអង្គប្រជុំអំពីលទ្ធផលនៃជំនួយបច្ចេកទេស និងការសិក្សាចំណាយប្រយុទ្ធនឹងជំងឺអេដស៍ ដែលក្នុងនោះការចំណាយសម្រាប់វិស័យអេដស៍៣១.៥លានដុល្លារអាមេរិកនៅឆ្នាំ២០១៦ និង៣៤.៥លានដុល្លារអាមេរិកឆ្នាំ២០១៧ និងដើម្បីជានានិរន្តរភាពរាជរដ្ឋាភិបាលត្រូវចូលរួមបដិភាគ៨.០លានដុល្លារអាមេរិកនៅឆ្នាំ២០១៦ និង៨.៣លានដុល្លារអាមេរិកនៅឆ្នាំ២០១៧ ហើយការចំណាយរួមរបស់រាជរដ្ឋាភិបាលនឹងកើនពី៨.៣លានដុល្លារអាមេរិកដល់១៣.៦៣លានដុល្លាអាមេរិកនៅឆ្នាំ២០២៣។

លោកវេជ្ជ. ស្រី មុនី បានបង្ហាញពីការវិវឌ្ឍក្នុងការអនុវត្តសេចក្តីជូនដំណឹងលេខ២១៣ស.ជ.ណ ដូចជា៖

- បានប្រជុំអន្តរក្រសួងក្នុងនោះ ក្រសួងមហាផ្ទៃបានទទួលស្គាល់ថា ការដាក់បញ្ចូលការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងផែនការអភិវឌ្ឍ ឃុំ សង្កាត់ ជារឿងត្រឹមត្រូវ ។
- តាមរយៈការសិក្សាវាយតម្លៃពីការដាក់បញ្ចូលការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ក្នុងផែនការអភិវឌ្ឍ ឃុំ សង្កាត់ បានចេញសេចក្តីពន្យល់បន្ថែមសម្រាប់ក្រសួងមហាផ្ទៃចេញគោលការណ៍ណែនាំឃុំ សង្កាត់ ជំហានបន្ទាប់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយក្រសួងមហាផ្ទៃតាមដានការអនុវត្តនៅថ្នាក់ក្រោមជាតិ ។
- កំណត់សកម្មភាពដែលត្រូវអនុវត្តតាមវិធានការនីមួយៗក្នុងសេចក្តីជូនដំណឹងលេខ២១៣ស.ជ.ណ ជាពិសេសវិធានការនីមួយៗសុទ្ធតែមានសកម្មភាពបន្ទាប់ដែលត្រូវអនុវត្ត។

**ឯកឧត្តម ឈឹម ឃិនជារ៉េត** អគ្គលេខាធិការប្រធានអង្គប្រជុំ បានថ្លែងអំណរគុណជូនដល់ សមាជិក សមាជិកាក្រុមប្រឹក្សាបច្ចេកទេសនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានចូលរួមបច្ចេកទេសក្នុងកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលពហុវិស័យប្រយុទ្ធនឹងជំងឺអេដស៍ និងសូមបន្តសម្របសម្រួលកិច្ចការ ដែលនៅសេសសល់មិនទាន់បានបញ្ចប់។ ឯកឧត្តមក៏បានស្នើសុំ សមាជិក សមាជិកាក្រុមប្រឹក្សាបច្ចេកទេស ជំរុញលទ្ធភាព កំណត់ និងដាក់បញ្ចូលបទអន្តរាគមន៍សកម្មភាពឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងផែនការប្រតិបត្តិរបស់ក្រសួង ស្ថាប័ន។៨

ចុងបញ្ចប់ ឯកឧត្តមប្រធានអង្គប្រជុំ បានអំពាវនាវស្នើសុំជំនួយពីដៃគូអភិវឌ្ឍ និងម្ចាស់ជំនួយ សូមជួយផ្តល់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុដល់ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិ ដើម្បីពង្រឹងសមត្ថភាពតាមរយៈការបណ្តុះបណ្តាល ចែករំលែកបទពិសោធន៍ ចំណេះដឹងបច្ចេកទេសរវាងផ្នែកពាក់ព័ន្ធឱ្យបានកាន់តែស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ។

កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានកំណត់កាលបរិច្ឆេទសម្រាប់កិច្ចប្រជុំលើកទី២ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០។

**ឧបសម្ពន្ធ៖**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ថ្ងៃពុធ ទី១២កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ភ្នំពេញ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០

បានឃើញ និងពិនិត្យផ្ទៀងផ្ទាត់

**អគ្គលេខាធិការ**

ឈឹម ឃិនដារ៉េត

បានពិនិត្យត្រឹមត្រូវ

**ប្រធាននាយកដ្ឋាន**

**ទាក់ទង និងចលនាប្រភពធនធាន**

**អ្នកធ្វើរបាយការណ៍**